បរិច្ឆេទទី៦ រូបបរមត្ថសង្គហវិភាគ

សម្តែងរូបសង្គហៈ ដោយន័យ ៥ គឺ

១- រូបសមុទ្ទេស សម្តែងរូបដោយសង្ខេប ដើម្បីឱ្យជ្រាបលក្ខណៈ

២- រូបវិភាគ សម្តែងរូបពិស្តារ ដោយចែកជាគូៗ

៣- រូបសមុដ្ឋាន សម្តែងហេតុកើតរូប ដោយសមុដ្ឋាន ៤

៤- រូបកលាប សម្តែងរូបជាកលាប មានចក្ខុកលាបជាដើម

៥- រូបបវត្តិក្កម សម្តែងលំដាប់ការប្រព្រឹត្តិទៅរបស់រូប ដោយការផ្សេងគ្នា

នៃភព កាល និងសត្ត្ব ដែលកើតក្នុងភូមិផ្សេងៗ។

រូបន័យទី១-រូបសមុទ្ទេស

រូប២៨ចែកជា១១ពួកគឺ៖

១-មហាភូតរូប៤	បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ
២-ប្រសាទរូប៥	ចក្ខុប្រសាទ, សោតប្រសាទ, ឃានប្រសាទ, ជិវ្ហាប្រសាទ, កាយប្រសាទ
៣-វិសយរូប៤	វណ្ណៈ, សទ្ទៈ, គន្ធៈ, រសៈ
៤-ភាវរូប២	ឥត្ថីភាវៈរូប, បុរិសភាវៈរូប
៥-ហទយរូប១	ហទយវត្ថុ
៦-ជីវិតរូប១	ជីវិតិន្ទ្រិយ
៧-អាហាររូប១	កពឡិង្ការាហារ
៨-បរិច្ឆេទរូប១	អាកាសធាតុ
៩-វិញ្ញត្តិរូប២	កាយវិញ្ញត្តិ, វចីវិញ្ញត្តិ
១០-វិការរូប៣	លហុតារូប, មុទុតារូប, កម្មញ្ញតារូប
១១-លក្ខណរូប៤	ឧបចយរូប, សន្តតិរូប, ជរតារូប, អនិច្ចតារូប

សណ្ឋាននៃបសាទរូបទាំង៥

១-ចក្ខុបសាទរូប មានសណ្ឋានប្រមាណប៉ុនក្បាលចៃ ក្នុងកណ្តាលនៃរង្វង់ភ្នែកខ្មៅ
ដែលព័ទ្ធជុំវិញដោយគ្រាប់ភ្នែកពណ៍ស របស់សសម្ភារចក្ខុ។

២-សោតបសាទរូប មានសណ្ឋាន ដូចវង់ចិញ្ជៀន មានរោមក្រហមល្អិតដុះទ្បើង
ខាងក្នុងប្រហោងសសម្ភារសោត:។

៣-ឃានបសាទរូប មានសណ្ឋានដូចក្រចកពពែ ខាងក្នុងប្រហោងនៃសសម្ភារឃាន:។

៤-ជិវ្ហាបសាទរូប មានសណ្ឋានដូចត្របកផ្កាឧប្បល នៅក្នុងប្រទេសនៃសសម្ភារជិវ្ហា។

៥-កាយបសាទរូប វៀរត្រង់ទីតាំងនៃតេជោធាតុដែលកើតអំពីកម្ម (បាចកតេជោ)
ដែលជាទីរួមនៃអាហារថ្មី ក្រោមពោះវៀនធំ ដែលជាស្ថានទីរបស់តេជោធាតុ
និងវៀរចុងសក់ ចុងរោម និងស្បែកក្រិនតាំងនៅទូទៅ។

ចក្ខុទ្វារ, ចក្ខុវត្ថុ, ចក្ខុធាតុ, ចក្ខ្វាយតន, ចក្ខុន្ទ្រិយ និងចក្ខុលោក
មានអង្គធម៍ដូចគ្នាគឺ បានដល់ចក្ខុបសាទរូប។
បសាទរូប៤ទៀតដែលនៅសល់ ក៏មានន័យច្រើនដូច និងចក្ខុបសាទរូបដែរ។

<u>រូបឆ័យទី២-រូបវិភាគ</u>

ឯកវិធឆ័យ

រូបទាំងអស់ ២៨ មានឈ្មោះ ៨ យ៉ាង ៖

១- ឈ្មោះថា អហេតុក: ព្រោះមិនមាន អលោភហេតុជាដើម មកសម្បយុត្ត

២- ឈ្មោះថា សប្បច្ចយ: ព្រោះមាន កម្មជាដើម ជាបច្ច័យ

៣- ឈ្មោះថា សាសវ: ព្រោះប្រព្រឹត្តទៅជាមួយ កាមាសវ:ជាដើម ដែលប្រារព្ធខ្លួនប្រព្រឹត្តទៅ

៤- ឈ្មោះថា សង្ខត: ព្រោះមាន កម្មជាដើម តាក់តែង

៥- ឈ្មោះថា លោកិយ: ព្រោះជាធម៌សង្គ្រោះចូលក្នុង សង្ខារលោក នៃឧបាទានក្ខន្ធ

៦- ឈ្មោះថា កាមាវចរ: ព្រោះជាទីត្រាច់ទៅ នៃកាមតណ្ហា

៧- ឈ្មោះថា អនារម្មណ: ព្រោះអត្ថថា មិនដឹងអារម្មណ៍

៨- ឈ្មោះថា អប្បហាតព្ព: ព្រោះមិនមែនជាធម៌ ត្រូវលះដោយ តទង្គប្បហានជាដើម ។

អភិធម្មត្ថសង្គហ: បរិច្ឆេទទី៦ (ភិក្ខុ គង់ សុមិត្ត) ទំព័រ - ៧៣១

ទុកន័យ មាន ១១ គូ

ទុកន័យ១១គូ / រូប២៨	មហាភូតរូប ៤	បសាទរូប ៥	វិសយរូប ៤	ភាវរូប ២	ហទយរូប ១	ជីវិតរូប ១	អាហាររូប ១	បរិច្ឆេទរូប ១	វិញ្ញត្តិរូប ២	វិការរូប ៣	លក្ខណរូប ៤	សរុប
អជ្ឈត្តិករូប ពាហិររូប ២៣		៥										៥
ចត្ថុរូប អវត្ថុរូប ២២		៥			១							៦
ទ្វាររូប អទ្វាររូប ២១		៥							២			៧
ឥន្ទ្រិយរូប អនិន្ទ្រិយរូប ២០		៥		២		១						៨
ឱឡារិករូប សុខុមរូប ១៦	៣ (ដកអាបោធាតុ)	៥	៤									១២
សន្តិកេរូប ទូជរូប ១៦	៣ (ដកអាបោធាតុ)	៥	៤									១២
សប្បដិឃរូប អប្បដិឃរូប ១៦	៣ (ដកអាបោធាតុ)	៥	៤									១២
ឧបាទិន្នរូប អនុបាទិន្នករូប ១០	៤	៥	៣ (ដកសទ្ទរូប)	២	១	១	១	១				១៨
សនិទស្សនរូប អនិទស្សនរូប ២៧			រូបារម្មណ៍									១
គោចរគាហិករូប អគោចរគាហិករូប ២៣		៥										៥
អចិនិញ្ជោគរូប វិនិញ្ជោគរូប ២០	៤		៣ (ដកសទ្ទរូប)				១					៨

រូបន័យទី៣-រូបសមុដ្ឋាន

វិញ្ញត្តិរូប២ កើតដោយចិត្ត ៣២ដួង

បុថុជ្ជន ព្រះសេក្ខបុគ្គល និងអសេក្ខបុគ្គល រមែងឱ្យវិញ្ញត្តិរូបទាំង ២ កើតដោយចិត្ត ៣២ដួងគឺ៖

- កាមាវចរកុសលចិត្ត ៨ដួង
- អភិញ្ញាចិត្ត ២ដួង
- អកុសលចិត្ត ១២ដួង
- មហាកិរិយាចិត្ត ៨ដួង
- បរិត្តកិរិយាចិត្ត ២ដួង (អហេតុកកិរិយា ដែលប្រកបដោយឧបេក្ខា)

សមុដ្ឋានដែលរូបមាន ៤

១- អតីតកម្ម	បានដល់ ចេតនា ២៥
២- ចិត្ត	បានដល់ ចិត្តុប្បាទ ៧៥ (រៀរចិត្ត ១៤)
៣- ឧតុ	បានដល់ ភាពក្តៅ និងភាពត្រជាក់
៤- អាហារ	បានដល់ ឱជាដែលមាននៅ ទាំងខាងក្នុងទាំងខាងក្រៅ

អភិធម្មត្ថសង្គហ: បរិច្ឆេទទី៦ (ភិក្ខុ គង់ សុមិត្ត) ទំព័រ - ៧៤០

តារាងចែករូប ២៨ ដោយសមុដ្ឋាន ៤

សមុដ្ឋាន ៤ / រូប ២៨	មហាភូតរូប ៤	បសាទរូប ៥	វិសយរូប ៤	ភាវរូប ២	ហទយរូប ១	ជីវិតរូប ១	អាហាររូប ១	បរិច្ឆេទរូប ១	វិញ្ញត្តិរូប ២	វិការរូប ៣	លក្ខណរូប ៤	សរុប
កម្មជ្ជរូប ១៨	៤	៥	៣*	២	១	១	១	១				**១៨**
ចិត្តជ្ជរូប ១៥	៤		៤				១	១	២	៣		**១៥**
ឧតុជ្ជរូប ១៣	៤		៤				១	១		៣		**១៣**
អាហារជ្ជរូប ១២	៤		៣*				១	១		៣		**១២**

៣* មានវណ្ណ:១, គន្ធ:១ និងរស:១ (ឡៀរសទ្ទ:)

- លេខដែលមានពណ៌បៃតង គឺជារូបដែលមានសមុដ្ឋានតែមួយ

ចិត្តជ្ជរូបមាន ៧ យ៉ាង

១- ចិត្តជ្ជរូប ដែលជាសាមញ្ញ មានការដកដង្ហើមចូល-ចេញ ការលោតរបស់បេះដូង ជីពចរ ជាដើម។ បានដល់ចិត្ត ៧៥ដួង (រឿរទ្វិបញ្ចវិញ្ញាណ១០និងអរូបវិបាក៤) មានរូបកើត ៨

២- ចិត្តជ្ជរូប ដែលជាប់ទាក់ទងជាមួយការសើច បានដល់ចិត្ត ១៣ដួង

៣- ចិត្តជ្ជរូប ដែលជាប់ទាក់ទងជាមួយការយំ បានដល់ទោសមូលចិត្ត ២ដួង

៤- ចិត្តជ្ជរូប ដែលជាប់ទាក់ទងជាមួយការកម្រើកញ្ចរកាយ មានការបត់ លា ឱន ងើប ក្រឡេកធ្វេង-ស្តាំ បានដល់ចិត្ត ៣២ដួង (មនោទ្វារាវជ្ជនចិត្ត១ កាមជវនចិត្ត២៩ និងអភិញ្ញាចិត្ត២)

៥- ចិត្តជ្ជរូប ដែលជាប់ទាក់ទងជាមួយការនិយាយ បានដល់ចិត្ត ៣២ដួង ដូចទី៤ដែរ

៦- ចិត្តជ្ជរូប ដែលជាប់ទាក់ទងជាមួយតរិយាបថធំ ៤ បានដល់ចិត្ត ៣២ដួង (ដូចទី៤ដែរ)

៧- ចិត្តជ្ជរូប ដែលជាប់ទាក់ទងជាមួយតរិយាបថធំ ៤ ដែលតាំងមាំ បានដល់ចិត្ត ៥៨ដួង

ចែកសមុដ្ឋាន ៤ ក្នុងកោដ្ឋាស ៤២

១- មានកម្ម ជាសមុដ្ឋាន មាន ១ គឺ *បាចកតេជោ*

២- មានចិត្ត ជាសមុដ្ឋាន មាន ១ គឺ *អស្សាសបស្សាសវាយោ*

៣- មានឧតុ ជាសមុដ្ឋាន មាន ៤ គឺ *ឧទរិយំ ករិសំ បុញ្ញោ មុត្តំ*

៤- មានចិត្ត និងឧតុ ជាសមុដ្ឋាន មាន គឺ *សេទោ អស្សុ ខេឡោ សង្ឃាណិកា*

៥- មាន ៤ សមុដ្ឋាន គឺ កោដ្ឋាស ៣២ ដែលនៅសល់ ។

សមុដ្ឋាន ៤ ក្នុងកោដ្ឋាស ៤២

សមុដ្ឋាន ៤ / កោដ្ឋាស ៤២	កម្មសមុដ្ឋាន	ចិត្តសមុដ្ឋាន	ឧតុសមុដ្ឋាន	អាហារសមុដ្ឋាន	សរុបសមុដ្ឋាន
ឧបកគេដោ	១				១
អស្សាសបស្សាសនាយោ		១			១
ឧនរិយំ កវីសំ បុញ្ញោ មុត្តំ			៤		១
សេនោ អស្សុ ខេឡោ សិឡាណិកា		៤	៤		២
កោដ្ឋាស ៣២ ដែលនៅសល់	៣២	៣២	៣២	៣២	៤

រូបឆ័យទី៤-រូបកលាប

កម្មដ្ឋានកលាប ៩

	អវិនិព្ភោគរូប ៨					ជីវិតរូប ១	រូប ៨	សរុប
	មហាភូតរូប ៤	វណ្ណៈ១	គន្ធៈ១	រសៈ១	ឱជា១			
ចក្ខុទសកកលាប	៤	១	១	១	១	១	ចក្ខុប្រសាទរូប ១	១០
សោតទសកកលាប	៤	១	១	១	១	១	សោតប្រសាទរូប ១	១០
ឃានទសកកលាប	៤	១	១	១	១	១	ឃានប្រសាទរូប ១	១០
ជិវ្ហាទសកកលាប	៤	១	១	១	១	១	ជិវ្ហាប្រសាទរូប ១	១០
កាយទសកកលាប	៤	១	១	១	១	១	កាយប្រសាទរូប ១	១០
ឥត្ថីភាវទសកក	៤	១	១	១	១	១	ឥត្ថីភាវរូប ១	១០
បុរិសភាវទសកក	៤	១	១	១	១	១	បុរិសភាវរូប ១	១០
វត្ថុទសកកលាប	៤	១	១	១	១	១	ហទយរូប ១	១០
ជីវិតនវកកលាប	៤	១	១	១	១	១		៩

ចិត្តដ្ឋកលាប ៦

ចិត្តដ្ឋកលាប ៦ / ចិត្តជ្ជរូប ១៤	អវិនិព្ភោគរូប៨	កាយវិញ្ញត្តិរូប១	វចីវិញ្ញត្តិរូប១	សទ្ទរូប១	វិការរូប៣	សរុប
សុទ្ធដ្ឋកលាប	៨					៨
កាយវិញ្ញត្តិនវកកលាប	៨	១				៩
វចីវិញ្ញត្តិសទ្ទទសកកលាប	៨		១	១		១០
លហុតាទិឯកាទសកកលាប	៨				៣	១១
កាយវិញ្ញត្តិលហុតា ទិទ្វាទសកកលាប	៨	១			៣	១២
វចីវិញ្ញត្តិសទ្ទលហុតា ទិតេរសកកលាប	៨		១	១	៣	១៣

ឧត្ថុជ្ជកលាប ៤

ឧត្ថុជ្ជកលាប ៤ / ឧត្ថុជ្ជរូប ១២	អវិនិព្ពោគរូប៨	សទ្ទរូប១	វិការរូប៣	សរុប
សុទ្ធដ្ជកលាប	៨			៨
សទ្ទនវកកលាប	៨	១		៩
លហុតាទិឯកាទសកកលាប	៨		៣	១១
សទ្ទលហុតាទិទ្វាទសកកលាប	៨	១	៣	១២

អាហារជ្ជកលាប ២

អាហារជ្ជកលាប ២ / អាហារជ្ជរូប ១១	អវិនិព្ពោគរូប៨	វិការរូប៣	សរុប
សុទ្ធជ្ជកលាប	៨		៨
លហុតាទិឯកាទសកកលាប	៨	៣	១១

រូបកលាប ២១ ក្នុងអាការ ៤២

អាការ ៤២ / រូបកលាប ២១	កម្មជ្ជកលាប			ចិត្តជ្ជកលាប	ឧតុជ្ជកលាប	អាហារជ្ជកលាប	សរុប
	កាយទសកកលាប	ភាវទសកកលាប	ជីវិតនវកកលាប	ចិត្តសុទ្ធដ្ឋកកលាប	ឧតុសុទ្ធដ្ឋកកលាប	អាហារសុទ្ធដ្ឋកកលាប	
ឧទរិយំ ភរីសំ					៨		៨
សសម្ភារបឋវី ១៨ ឆៅសល់	១០	១០		៨	៨	៨	៤៤
បុញ្ញោ មុក្តំ					៨		៨
សេទោ អស្សុ ខេឡោ សិង្ឃាណិកា				៨	៨		១៦
សសម្ភារអាបោ ៦ នៅសល់	១០	១០		៨	៨	៨	៤៤
ឲបកតេជោ			៩				៩
សសម្ភារតេជោ ៣ ឆៅសល់			៩	៨	៨	៨	៣៣
អស្សាសបស្សាសវាយោ				៨			៨
សសម្ភារវាយោ ៥ នៅសល់			៩	៨	៨	៨	៣៣

រូបកលាប ២១ ក្នុងសសម្ភារៈរូប ៥

រូបកលាប ២១ / សសម្ភារៈរូប ៥	កម្មសមុដ្ឋាន			ចិត្តសមុដ្ឋាន	ឧតុសមុដ្ឋាន	អាហារសមុដ្ឋាន	សរុប
	ចក្ខុទសក កលាប	ភាវទសក កលាប	កាយទសក កលាប	ចិត្តសុទ្ធដ្ឋក កលាប	ឧតុសុទ្ធដ្ឋក កលាប	អាហារសុទ្ធដ្ឋក កលាប	
ចក្ខុសសម្ភារៈ	១០	១០	១០	៨	៨	៨	៥៤
សោតសសម្ភារៈ	១០	១០	១០	៨	៨	៨	៥៤
ឃានសសម្ភារៈ	១០	១០	១០	៨	៨	៨	៥៤
ជិត្ហាសសម្ភារៈ	១០	១០	១០	៨	៨	៨	៥៤
កាយសសម្ភារៈ		១០	១០	៨	៨	៨	៤៤

រូបន័យទី៥-រូបបវត្តិក្នុម

សម្តែងការកើតឡើងដំបូង ការកើតចុងក្រោយ និងការរលត់គ្រាចុងក្រោយ របស់កម្មជ្ជរូប



សម្តែងការកើតឡើងដំបូង ការកើតចុងក្រោយ និង ការរលត់ក្រោចុងក្រោយ របស់ចិត្តជ្ជរូប



សម្តែងការកើតឡើងដំបូង ការកើតចុងក្រោយ និង ការរលត់គ្រាចុងក្រោយ របស់ឧតុជរូប



ឧតុជរូប របស់ពួកសំសេទជៈ និង គព្ភសេយ្យកៈ នៅតែកើតបានសូម្បីជាសាកសព រហូតដល់កប្បវិនាសទើបរលត់អស់ ចំណែកពួកឱបបាតិកកំណើត កាលបើស្លាប់ឧតុជ-រូបរមែងរលត់ទៅព្រមគ្នានឹងចុតិចិត្ត ព្រោះកំណើតពួកនេះមិនបានបន្សល់សាកសពទុក។

ឧតុជរូប កើតគ្រាដំបូងត្រង់ឋិតិខណៈរបស់បដិសន្ធិចិត្ត ហើយនឹងកើតបន្តទៅគ្រប់ៗ អនុខណៈរបស់ចិត្ត។

សម្តែងការកើតឡើងដំបូង ការកើតចុងក្រោយ និង ការលត់ក្រាចុងក្រោយ របស់អាហារជ្ជូរូប



កាលបន្តនៃរូបកណ្ឌបរបស់សត្វពីបដិសន្ធិកាល



អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៦ (ភិក្ខុ គង់ សុមិត្ត) ទំព័រ - ៧៦៩

បទត្តិក្អមន័យ មានអត្ថសម្តែងលំដាប់នៃការប្រព្រឹត្តិទៅ

របស់រូបដោយអាការ ៣ យ៉ាងគឺ៖

១- សម្តែងរូបដោយភូមិ ២៧

២- សម្តែងរូបដោយកាល ៣

៣- សម្តែងរូបដោយកំណើត ៤

តារាងរូបដោយភូមិ ២៧

ភូមិ ២៣ / រូប២៨	មហាភូតរូប ៤	បសាទរូប ៥	វិសយរូប ៤	ភាវរូប ២	ហទយរូប ១	ជីវិតរូប ១	អាហាវរូប ១	បរិច្ឆេទរូប ១	វិញ្ញត្តិរូប ២	វិការរូប ៣	លក្ខណរូប ៤	សរុប
ភាមភូមិ ១១	៤	៥	៤	១*	១	១	១	១	២	៣	៤	២៧
រូបភូមិ ១៥	៤	២**	៤	X	១	១	១	១	២	៣	៤	២៣
អសញ្ញសត្តភូមិ	៤	X	៣***	X	X	១	១	១	X	៣	៤	១៧
អរូបព្រហ្ម ៤	មិនមានរូបកើត (មានតែនាមធម៌)											

១* បើមានឥត្ថីភាវរូប គឺមិនមានបុរិសភាវរូប, បើមានបុរិសភាវរូប គឺមិនមានឥត្ថីភាវរូបទេ

២** មានតែចក្ខុបសាទរូប១ និងសោតបសាទរូប១

៣*** មានវណ្ណ:១, គន្ធ:១ និងរស:១ (រឿរសទ្ទ:)

X រូបនោះមិនកើត

តារាងចែករូប២៨ ក្លុងកាមតូមិ១១ ដោយសមុដ្ឋាន៤

សមុដ្ឋាន ៤ / រូប២៨	មហាភូតរូប ៤	បសាទរូប ៥	វិសយរូប ៤	ភាវរូប ២	ហទយរូប ១	ជីវិតរូប ១	អាហាររូប ១	បរិច្ឆេទរូប ១	វិញ្ញត្តិរូប ២	វិការរូប ៣	លក្ខណរូប ៤	សរុប
កម្មជ្ជរូប ១៨	៤	៥	៣*	២	១	១	១	១				**១៨**
ចិត្តជ្ជរូប ១៥	៤		៤				១	១	២	៣		**១៥**
ឧតុជ្ជរូប ១៣	៤		៤				១	១		៣		**១៣**
អាហារជ្ជរូប១២	៤		៤					១		៣		**១២**

៣* មានវណ្ណ:១, គន្ធ:១ និងរស:១ (ឡៀរសទ្ទ:)

- លេខដែលមានពណ៌បៃតង គឺជារូបដែលមានសមុដ្ឋានតែមួយ

អភិធម្មត្ថសង្គហ: បរិច្ឆេទទី៦ (ភិក្ខុ គង់ សុមិត្ត) ទំព័រ - ៧៧៣

តារាងចែករូប២៣ ក្លុងរូបតូមិ១៥ ដោយសមុដ្ឋាន៣

សមុដ្ឋាន ៤ / រូប២៨	មហាភូតរូប ៤	បសាទរូប ៥	វិសយរូប ៤	ភាវរូប ២	ហទយរូប ១	ជីវិតរូប ១	អាហាររូប ១	បរិច្ឆេទរូប ១	វិញ្ញត្តិរូប ២	វិការរូប ៣	លក្ខណរូប ៤	សរុប
កម្មជ្ជរូប ១៣	៤	២*	៣**	០	១	១	១	១				១៨
ចិត្តជ្ជរូប ១៥	៤		៤				១	១	២	៣		១៥
ឧតុជ្ជរូប ១៣	៤		៤				១	១		៣		១៣
អាហារជ្ជរូប	ពួកព្រហ្មបុគ្គល មិនបរិភោគអាហារ											

២* មានតែចក្ខុបសាទរូប១ និងសោតបសាទរូប១

៣** មានវណ្ណ:១, គន្ធ:១ និងរស:១ (ឡៀរសទ្ទ:)

- លេខដែលមានពណ៌បៃតង គឺជារូបដែលមានសមុដ្ឋានតែមួយ

តារាងចែករូប១៧ ក្នុងអសញ្ញសត្តភូមិ ដោយសមុដ្ឋាន២

សមុដ្ឋាន ៤ / រូប១៨	មហាភូតរូប ៥	បសាទរូប ៥	វិសយរូប ៤	ភាវរូប ២	ហទយរូប ១	ជីវិតរូប ១	អាហាររូប ១	បរិច្ឆេទរូប ១	វិញ្ញត្តិរូប ២	វិការរូប ៣	លក្ខណៈរូប ៤	សរុប
កម្មជៈរូប ១០	៤	០	៣*	០	០	១	១	១				១៨
ឧតុជៈរូប ១២	៤		៣*				១	១	០	៣		១៥
ចិត្តជៈរូប	ពួកអសញ្ញសត្តព្រហ្ម មិនមានចិត្ត											
អាហារជៈរូប	ពួកអសញ្ញសត្តព្រហ្ម មិនបរិភោគអាហារ											

* ៣ មានវណ្ណៈ១, គន្ធៈ១ និងរសៈ១ (រៀរសទ្ធៈ)

- លេខដែលមានពណ៌បៃតង គឺជារូបដែលមានសមុដ្ឋានតែមួយ

សម្ដែងរូប២៨ ដោយកំណើត គឺយោនិ មាន ៣ ឬ៤

យោនិ កំណើត ៣

១- សំសេទជកំណើត បានដល់ កើតក្នុងកម្ទេចក្អែល ក្នុងជ័រស្អិត ក្នុងផ្លែឈើ

២- ឧបបាតិកកំណើត បានដល់ កំណើតផុសឡើង ចម្រើនពេញទី (ធំពេញ រូបរាងភ្លាម)

៣- គព្ភសេយ្យកកំណើត បានដល់ កើតក្នុងភគ៌ មាន២គឺ អណ្ឌជកំណើត កើតក្នុងស៊ុត១

ជលាពុជកំណើត កើតក្នុងស្បូន១

យោនិ កំណើត ៤

១- សំសេទជកំណើត ២- ឧបបាតិកកំណើត

៣- អណ្ឌជកំណើត ៤- ជលាពុជកំណើត

ឧបបត្តិកន័យ

ក្នុងអភិធម្មវិភាវិនីដីកា អាចារ្យពួកខ្លះថា

សប្តាហ៍ទី១ ជាកលលៈ, សប្តាហ៍ទី២ ជាអព្ទុទៈ, សប្តាហ៍ទី៣ ជាបេសិ,

សប្តាហ៍ទី៤ ជាឃនៈ, សប្តាហ៍ទី៥ ជាបញ្ចសាខៈ, សប្តាហ៍ទី៦ ជាបរិបាក,

សប្តាហ៍ទី៧ កើតចក្ខុប្រសាទ, សប្តាហ៍ទី៨ កើតសោតប្រសាទ, សប្តាហ៍ទី៩ កើតឃានប្រសាទ,

សប្តាហ៍ទី១០ កើតជិវ្ហាប្រសាទ, សប្តាហ៍ទី១១ ជាដើម កើតកេសា លោមាជាដើម

ក្នុងមួយសប្តាហ៍ កើតអាការមួយៗ ដរាបដល់គ្រប់អាការ ៣២ របស់សត្វក្នុងគភ៌។

(សរុប ៤២ សប្តាហ៍)